# មគ្គុទ្ទេសក៍ណែនាំ

# ក្នុងការចុះម៉ោងធ្វើការរបស់អ្នកផ្តល់សេវាមើលថែក្នុងរដ្ឋអូរិហ្គិន

ការណែនាំនេះគឺសម្រាប់អ្នកទទួលការមើលថែ ជនតំណាងអ្នកទទួលការមើលថែ បុគ្គលិកមើលថែតាមផ្ទះ និងអ្នកមើលថែផ្ទាល់ខ្លួន។ វាមានរួមបញ្ចូលនូវព័ត៌មានអំពី៖

- របៀបចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធចុះម៉ោងធ្វើការតាមអេឡិចត្រូនិច ហៅថា OR PTC DCI (Oregon Provider Time Capture Direct Care Innovations) និង
- នរណាគេអាចជួយបានបើអ្នកត្រូវការជំនួយ។

## តារាងមាតិកា


**ទិដ្ឋភាពទូទៅ......................................................2**

**ជ្រើសរើសចុះម៉ោងធ្វើការ ..............................................3**

**ព័ត៌មានចូលក្នុងគណនី ................................................5**

**ចាប់ផ្តើមជាមួយជម្រើស OR PTC DCI នីមួយៗ..............................8**

**ត្រូវការជំនួយ?.....................................................10**

**សំណួរដែលគេសួរជាញឹកញាប់ (FAQs) ....................................12**

## ទិដ្ឋភាពទូទៅ

- OR PTC DCI ជាអក្សរកាត់ចេញពី Oregon Provider Time Capture Direct Care Innovations។ ប្រព័ន្ធគ្រប់គ្រងម៉ោងធ្វើការតាមអេឡិចត្រូនិចនេះបានជំនួសក្រដាសសរសេរបញ្ចូលម៉ោងធ្វើការ កាលពីខែកញ្ញា ឆ្នាំ 2021។
- ជាផ្នែកមួយនៃច្បាប់នៅសតវត្សន៍ទី 21 ដែលរដ្ឋាភិបាល សហព័ន្ធតម្រូវឱ្យប្រមូលព័ត៌មានជាក់លាក់តាមអេឡិចត្រូនិក នៅពេលផ្តល់សេវាមើលថែទាំផ្ទាល់ខ្លួន។ តម្រូវការនេះត្រូវបានគេហៅថាការផ្ទៀងផ្ទាត់ម៉ោងតាមអេឡិកត្រូនិក ឬ EVV ។
- OR PTC DCI ប្រមូលយកព័ត៌មានខាងក្រោមដើម្បីបំពេញតាមតម្រូវការ EVV របស់សហព័ន្ធ៖
    - ប្រភេទនៃសេវាកម្ម
    - ឈ្មោះអតិថិជនដែលកំពុងទទួលសេវាកម្ម
    - ឈ្មោះអ្នកផ្តល់សេវាមើលថែ
    - កាលបរិច្ឆេទនៃសេវាកម្ម
    - ទីតាំងនៃសេវាកម្ម និង
    - ម៉ោងចូល និងចេញពីធ្វើការ
- មានជម្រើស OR PTC DCI ផ្សេងៗគ្នា ក្នុងការជ្រើសរើសចុះពេលម៉ោងធ្វើការ។ អ្នកផ្តល់សេវាមើលថែ និងអ្នកទទួលការមើលថែ គួរតែធ្វើការរួមគ្នាដើម្បីស្វែងរកវិធីសាស្ត្រណាមួយដែលមានប្រសិទ្ធភាពបំផុតសម្រាប់អ្នកទាំងពីរ។ អ្នកប្រហែលជាអាចប្រើវិធីផ្សេងៗគ្នាបើចាំបាច់ ប៉ុន្តែអ្នកនឹងត្រូវជ្រើសរើសវិធីណាមួយក្នុងពេលតែមួយអំឡុងពេលម៉ោងធ្វើការរបស់អ្នក។ ឧទាហរណ៍ ប្រសិនបើអ្នកចូលប្រើកម្មវិធី

ក្នុងទូរស័ព្ទដៃដើម្បីចុះម៉ោងចូលធ្វើការ នោះអ្នកនឹងត្រូវចុះម៉ោងចេញពីធ្វើការជាមួយកម្មវិធីក្នុងទូរស័ព្ទដៃដែរ។

## ជម្រើសពីរសចុះម៉ោងធ្វើការ

### កម្មវិធី OR PTC DCI ក្នុងទូរស័ព្ទដៃ

កម្មវិធីក្នុងទូរស័ព្ទដៃដែលឥតគិតថ្លៃនេះគឺជាជម្រើសដ៏ពេញនិយមបំផុត។ អ្នកផ្ដល់សេវាមើលថែអាចប្រើកម្មវិធីក្នុងទូរស័ព្ទដៃជារៀងរាល់ថ្ងៃ ដើម្បីចុះម៉ោងចូល និងម៉ោងចេញពីធ្វើការ មើលចំនួនម៉ោងធ្វើការសរុប និងសរសេរកំណត់ត្រាផ្សេងៗ។ នៅក្នុងកម្មវិធីទូរស័ព្ទដៃ អ្នកទទួលការមើលថែមិនចាំបាច់ធ្វើអ្វីទាំងអស់ ប៉ុន្តែអាចសុំមើលម៉ោងផ្ទៀងផ្ទាត់បាន ប្រសិនបើគាត់ចង់។ អ្នកទទួលការមើលថែមានជម្រើសក្នុងការចុះហត្ថលេខាដោយប្រើលេខកូដ PIN/ពាក្យសម្ងាត់ ឬចុះហត្ថលេខាអេឡិចត្រូនិក ឬគាត់ក៏អាចមិនចាំបាច់ធ្វើអ្វីទាំងអស់នោះទេ។

កម្មវិធីក្នុងទូរស័ព្ទដៃអាចចូលប្រើបានសម្រាប់ជនដែលមានពិការភាព ហើយមានជាភាសាអង់គ្លេស អេស្ប៉ាញ រុស្ស៊ី ចិន វៀតណាម អារ៉ាប់ និងសូម៉ាលី (ភាសាជាច្រើនទៀតនឹងត្រូវបានគេបន្ថែមជាបន្តបន្ទាប់)។ កម្មវិធីក្នុងទូរស័ព្ទដៃក៏អាចប្រើបានដោយមិនចាំបាច់មានអ៊ីនធឺណិត ដើម្បីឱ្យអ្នកផ្ដល់សេវាមើលថែអាចចូល ចុះម៉ោងចូលនិងចេញពីធ្វើការដោយមិនចាំបាច់ភ្ជាប់អ៊ីនធឺណិតផងដែរ។ អ្នកផ្ដល់សេវាមើលថែអាចចុះម៉ោងបានរហូតដល់ 10 ដង សម្រាប់រយៈពេលរហូតដល់ 5 ថ្ងៃជាប់ៗគ្នាដោយមិនមានអ៊ីនធឺណិត ឬ ភ្ជាប់ជាមួយវ៉ាយហ្វាយ។ សូមចុចរក **OR PTC DCI** នៅក្នុង Apple App Store ឬនៅលើ Google Play សម្រាប់អ្នកប្រើ Android។

រូបតំណាង OR PTC DCI ក្នុងកម្មវិធីទូរស័ព្ទដៃ PTC DCI៖

## OR PTC DCI តាមទូរស័ព្ទលើតុ

ប្រសិនបើអ្នកផ្តល់សេវាមើលថែមិនមានទូរស័ព្ទដៃ ឬអាយផាត ហើយអ្នកទទួលការមើលថែមានទូរស័ព្ទលើតុ នោះ OR PTC DCI តាមទូរស័ព្ទលើតុគឺជាជម្រើសដ៏ល្អមួយ។ អ្នកផ្តល់សេវាមើលថែអាចប្រើទូរស័ព្ទលើតុរបស់អ្នកទទួលការមើលថែដើម្បីវាយបញ្ចូលម៉ោងធ្វើការរបស់ពួកគេដោយធ្វើតាមការណែនាំតាមទូរស័ព្ទ។ វាអាចត្រូវបានប្រើសម្រាប់ការវាយបញ្ចូលម៉ោងធ្វើការតាមពេលជាក់ស្តែង ឬដើម្បីបញ្ចូលម៉ោងធ្វើការកាលពីមួយថ្ងៃមុន។ ចំណាំ៖ ដើម្បីប្រើជម្រើសនេះ លេខទូរស័ព្ទរបស់អ្នកទទួលការមើលថែ ត្រូវតែដូចគ្នាជាមួយនឹងលេខទូរស័ព្ទដែលមានចុះក្នុងឯកសារនៅក្រសួង ODHS/OHA។

លេខខ្សែទូរស័ព្ទ OR PTC DCI គឺ៖

- ជាភាសាអង់គ្លេស និងអេស្ប៉ាញ៖ 844-856-9560
- ជាភាសាអង់គ្លេស និងវៀតណាម៖ 833-640-1295
- ជាភាសាអង់គ្លេស និងរុស្ស៊ី៖ 844-334-7318
- ជាភាសាអង់គ្លេស និងចិនកុកងឺ៖ 844-331-0241

- ជាភាសាអង់គ្លេស និងអារ៉ាប់៖ 844-311-4160

## ប្រអប់ fob ពី OR PTC DCI

ប្រសិនបើអ្នកទទួលការមើលថែមិនមានទូរស័ព្ទលើតុទេ ហើយគ្មាននរណាម្នាក់អាចចូលប្រើទូរស័ព្ទដៃបានទេ នោះអ្នកផ្តល់សេវាមើលថែអាចចុះម៉ោងបានដោយប្រើប្រអប់ fob។ fob គឺជាឧបករណ៍តូចមួយដែលត្រូវរក្សាទុកនៅក្នុងផ្ទះរបស់អ្នកទទួលការមើលថែ ដែលជាកន្លែងផ្តល់សេវាកម្ម។ fob មានលេខកូដ 6 ខ្ទង់ដែលហៅថា "tokens" នៅពេលចាប់ផ្តើម និងពេលបញ្ចប់ម៉ោងធ្វើការនីមួយៗ។ អ្នកផ្តល់សេវាមើលថែត្រូវកត់លេខកូដទាំងនេះជារៀងរាល់ថ្ងៃនៅលើសន្លឹកក្រដាស បន្ទាប់មកវាយបញ្ចូលលេខនោះតាមអេឡិចត្រូនិកទៅក្នុងវិបផតថល OR PTC DCI នៅ https://orptc.dcisoftware.com/ មុនថ្ងៃបញ្ចប់ពីរសប្តាហ៍ម្តង។ សម្រាប់អ្នកទទួលការមើលថែ គាត់មិនចាំបាច់ធ្វើអ្វីទេនៅពេលប្រើ fob។ ប្រសិនបើត្រូវការប្រអប់ fob នោះអ្នកទទួលការមើលថែ ឬអ្នកផ្តល់សេវាមើលថែត្រូវតែទាក់ទងទៅបុគ្គលិកកាន់សំណុំរឿងរបស់អ្នកទទួលការមើលថែ ដើម្បីដាក់សំណើសុំប្រអប់ fob។

សូមមើល មគ្គុទ្ទេសក៍យោង-ស្តីពីរបៀបប្រើប្រអប់ Fob ដើម្បីស្វែងយល់បន្ថែមអំពីរបៀបប្រើប្រអប់ fob។

រូបភាពនៃប្រអប់ fob៖




## ព័ត៌មានចូលក្នុងគណនី

អ្នកអាចចូលទៅក្នុង OR PTC DCI នៅពេលអ្នកទទួលបានការណែនាំនេះ។

**ព័ត៌មានសម្រាប់ចូលក្នុងគណនី OR PTC DCI តាមទូរស័ព្ទដៃ និងតាមវិបផតថល OR PTC DCI:**

**ឈ្មោះគណនីគឺជា៖ នាមខ្លួន.នាមត្រកូល**

**(ឧទាហរណ៍៖ john.smith)**

ឈ្មោះគណនីរបស់អ្នកជាទូទៅគឺជានាមខ្លួន និងនាមត្រកូលរបស់អ្នក។ ប្រសិនបើអ្នកមានការលំបាកក្នុងការចូលក្នុងគណនី សូមទាក់ទងទៅការិយាល័យក្នុងតំបន់របស់អ្នក។

**ពាក្យសម្ងាត់បណ្តោះអាសន្នគឺ៖ ORptc2021!**

សូមប្រើពាក្យសម្ងាត់បណ្តោះអាសន្ននេះជាលើកដំបូងដែលអ្នកចូលក្នុងគណនី បន្ទាប់មកវានឹងអោយអ្នកផ្លាស់ប្តូរពាក្យសម្ងាត់ទៅជាពាក្យសម្ងាត់ដែលអ្នកជ្រើសរើស។ នៅពេលផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នក សូមចងចាំនូវច្បាប់នៃពាក្យសម្ងាត់ដូចខាងក្រោម។ ពាក្យសំងាត់របស់អ្នក៖

- ត្រូវតែមានយ៉ាងហោចណាស់ 10 តួអក្សរ
- ត្រូវតែមានអក្សរធំ អក្សរធម្មតា និងសញ្ញាណាមួយ
- មិនអាចមានតួអក្សរច្រំដែលពីរដងទេ
- មិនអាចមានតួអក្សរច្រំដែល ដូចគ្នាពីរដងជាមួយនឹងឈ្មោះគណនីរបស់អ្នកទេ

<u>ឧទាហរណ៍៖</u> ប្រសិនបើឈ្មោះគណនីរបស់អ្នកគឺ john.smith, មិនអាចប្រើពាក្យសម្ងាត់ថា JSmith175qw4! បានទេ ព្រោះវាមានយ៉ាងហោចណាស់តួអក្សរ 3 ដូចគ្នានឹងឈ្មោះគណនីរបស់អ្នក។

អ្នកត្រូវតែផ្លាស់ប្តូរពាក្យសម្ងាត់ OR PTC DCI របស់អ្នករៀងរាល់ 60 ថ្ងៃម្តង ហើយអ្នកមិនអាចប្រើពាក្យសម្ងាត់ 24 ដងចុងក្រោយរបស់អ្នកបានទេ។

**លេខ PIN**

លេខ PIN នឹងត្រូវគេកំណត់ក្នុងគណនីទាំងអស់ ដោយផ្អែកលើលេខបួនខ្ទង់ចុងក្រោយនៃលេខទូរស័ព្ទផ្ទះរបស់អ្នក។ ប្រសិនបើមិនមានលេខទូរស័ព្ទផ្ទះនៅលើឯកសារទេ នោះលេខ PIN គឺជាលេខ 0000។ លេខ PIN នេះត្រូវបានប្រើដើម្បីចុះម៉ោងចូល ឬចេញពីធ្វើការនៅក្នុងកម្មវិធីទូរស័ព្ទដៃ ឬទូរស័ព្ទលើតុ។

## ចាប់ផ្តើមជាមួយជម្រើស OR PTC DCI នីមួយៗ

### កម្មវិធីក្នុងទូរស័ព្ទដៃ OR PTC DCI

ប្រសិនបើអ្នកចង់ប្រើកម្មវិធី OR PTC DCI ក្នុងទូរស័ព្ទដៃ អ្នកគ្រាន់តែដោនឡូតយកកម្មវិធីនេះដោយឥតគិតថ្លៃនៅលើទូរសព្ទដៃរបស់អ្នក។ អាបក្នុងទូរស័ព្ទដៃធ្វើតម្រូវជាមួយទូរស័ព្ទ Android លេខ 8 និងខ្ពស់ជាងនេះ និងកម្មវិធី Apple លេខ 13 និងខ្ពស់ជាងនេះ។

បន្ទាប់មកអ្នកអាចប្រើព័ត៌មានខាងលើដើម្បីចូលក្នុងគណនីរបស់អ្នកក្នុងកម្មវិធីទូរស័ព្ទដៃ។

### OR PTC DCI ទូរស័ព្ទលើតុ

<u>អ្នកទទួលការមើលថែ៖</u> សូមប្រាកដថាមានលេខទូរសព្ទ័ត្រឹមត្រូវនៅលើឯកសារជាមួយក្រសួង ODHS/OHA។ ប្រសិនបើលេខរបស់អ្នកស្ថិតនៅក្នុងឯកសារ ហើយព័ត៌មានរបស់អ្នកត្រូវបានគេបញ្ចូលនៅក្នុង OR PTC DCI នោះមិនមានសកម្មភាពផ្សេងទៀតដែលអ្នកត្រូវធ្វើសម្រាប់ជម្រើសប្រើទូរស័ព្ទលើតុនោះទេ។

ប្រសិនបើអ្នកជួបបញ្ហាណាមួយ ឬត្រូវការជំនួយ សូមប្រាកដថាអ្នកកំពុងប្រើលេខទូរស័ព្ទដូចគ្នាជាមួយលេខដែលមានក្នុងឯកសាររបស់ក្រសួង ODHS/OHA សម្រាប់អ្នកទទួលការមើលថែ។

ប្រសិនបើអ្នកនៅតែត្រូវការជំនួយ សូមទូរស័ព្ទទៅផ្នែកជំនួយបច្ចេកទេស DCI តាមរយៈលេខ 1-855-565-0155 ឬអ៊ីមែលទៅ ORPTCSupport@dcisoftware.com ។

### ប្រអប់ fob ពី OR PTC DCI

ប្រសិនបើអ្នកផ្តល់សេវាមិនមានលទ្ធភាពចូលប្រើទូរស័ព្ទដៃ ឬអាយផាត ហើយអ្នកទទួលការមើលថែមិនមានទូរស័ព្ទលើតុទេ ជម្រើសមួយផ្សេងទៀតគឺប្រើប្រអប់ fob ពី OR PTC DCI។ ប្រសិនបើត្រូវការប្រអប់ fob អ្នកទទួលការមើលថែត្រូវតែស្នើសុំវាពីការិយាល័យក្នុងតំបន់ដែលគាត់រស់នៅ។ វាប្រហែលជាអាចចំណាយពេលជាច្រើនសប្តាហ៍សម្រាប់អ្នក

ទទួលការមើលថែដើម្បីទទួលបានប្រអប់ fob តាមបុស្តិ៍សំបុត្រ។ ខណៈពេលដែលកំពុងរង់ចាំប្រអប់ fob ផ្ញើមកដល់ អ្នកផ្តល់សេវាមើលថែអាចវាយបញ្ចូលម៉ោងជាបន្តបន្ទាប់នៅក្នុងវិបផតថលបាន។ សូមចំណាំថា ការវាយបញ្ចូលម៉ោងជាបន្តបន្ទាប់មិនត្រូវប្រើជាទៀងទាត់នោះទេ ប៉ុន្តែអាចប្រើវាបានតែនៅពេលណាដែលអ្នកផ្តល់សេវាមើលថែមិនអាចប្រើជម្រើសណាមួយក្នុងចំណោមជម្រើស EVV ប៉ុណ្ណោះ។

នៅពេលដែលបានទទួលប្រអប់ហើយ សូមធានាថាប្រអប់ fob ទុកនៅកន្លែងដែលមានសុវត្ថិភាពនៅក្នុងទីតាំងដែលអ្នកទទួលសេវាកម្ម។ អ្នកផ្តល់សេវាមើលថែគួរតែអាចចូលប្រើប្រអប់ fob បានយ៉ាងងាយស្រួលនៅពេលចាប់ផ្តើម និងចេញពីធ្វើការ។ អ្នកទទួលការមើលថែមិនចាំបាច់ធ្វើអ្វីផ្សេងទៀតទេ។

អ្នកផ្តល់សេវាមើលថែនឹងត្រូវកំណត់ត្រានូវលេខកូដ fob និងកាលបរិច្ឆេទ និងម៉ោងពេលធ្វើការ។ អ្នកអាចស្វែងរកតារាងវាយម៉ោងធ្វើការតាម fob ដើម្បីកត់ត្រាព័ត៌មាននេះនៅលើគេហទំព័រ PTC, PTC.Oregon.gov នៅក្នុងផ្នែក Learning Materials ។ តារាងម៉ោងពេលធ្វើការនេះមានសរសេរជាភាសាផ្សេងៗ។ ចំណាំ៖ តារាងម៉ោងពេលធ្វើការ Fob គឺសម្រាប់តែកំណត់ត្រារបស់អ្នកប៉ុណ្ណោះ ហើយមិនអាចយកកំណត់ត្រានោះទៅដាក់ក្នុងការិយាល័យក្នុងតំបន់បានទេ។ អ្នកត្រូវតែវាយបញ្ចូលព័ត៌មាននៃម៉ោងធ្វើការ និងលេខកូដ fob របស់អ្នកទៅក្នុងវិបផតថល ដើម្បីទទួលបានការបង់ប្រាក់សម្រាប់ពេលវេលាដែលអ្នកបានធ្វើការ។

ប្រសិនបើអ្នកបានទទួលប្រអប់ fob ដែលមិនដើរ ឬដើរមិនត្រូវ សូមទាក់ទងទៅ PTC.Support@odhsoha.oregon.gov ឬការិយាល័យក្នុងតំបន់របស់អ្នក។

## ត្រូវការជំនួយ?

កាតាឡុកសម្ភារៈសិក្សាសំរាប់អ្នកផ្តល់សេវាមើលថែ មានរាយនូវធនធានសិក្សាជាច្រើនសម្រាប់អ្នកផ្តល់សេវាមើលថែ រួមទាំង មគ្គុទ្ទេសក៍សំរាប់អ្នកផ្តល់សេវាមើលថែ, ការណែនាំជាច្រើន (QRGs), ការរៀនតាមអនឡាញ និងជាវីដេអូបង្ហាញជាដើម។

កាតាឡុកសម្ភារៈសិក្សាសំរាប់អ្នកផ្តល់សេវាមើលថែមានបកប្រែជាភាសា៖

### ជំនួយសម្រាប់បុគ្គលិកមើលថែតាមផ្ទះ (HCWs)

បុគ្គលិកមើលថែតាមផ្ទះគឺជាអ្នកផ្តល់សេវាមើលថែតាមផ្ទះដែលសេវាកម្មរបស់ពួកគេត្រូវបានគេអនុញ្ញាតតាមរយៈក្រសួងសង្គមកិច្ចនៃរដ្ឋអូរិហ្គិន (ODHS)។

សូម**ទាក់ទងទៅការិយាល័យ ODHS ក្នុងតំបន់របស់អ្នក** ប្រសិនបើអ្នកមានសំណួរអំពីគម្រោងសេវាកម្ម កិច្ចការងារម៉ោងដែលបានអនុញ្ញាត គោលការណ៍ បច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនង ឬទើបតែចាប់ផ្តើមធ្វើជាអ្នកផ្តល់សេវាមើលថែ ឬជាអ្នកទទួលការមើលថែថ្មី។

សូមទាក់ទងទៅគណៈកម្មាការផ្តល់កិច្ចគាំពារមើលថែតាមផ្ទះក្នុងរដ្ឋអូរិហ្គិន សម្រាប់សំណួរទំនាក់ទំនងអតិថិជន និងផ្តល់ជាមតិយោបល់ ដោយប្រើ**បែបបទផ្តល់មតិយោបល់ដល់ OHCC** តាមអនឡាញ។

### ជំនួយសម្រាប់អ្នកមើលថែផ្ទាល់ខ្លួន

អ្នកមើលថែសុខភាពផ្ទាល់ខ្លួនគឺជាអ្នកផ្តល់សេវាថែទាំសុខភាពតាមផ្ទះដែលមានការអនុញ្ញាតតាមរយៈអាជ្ញាធរសុខភាពនៃរដ្ឋអូរិហ្គិន (OHA)។

ប្រសិនបើអ្នកជាសមាជិកថ្មី ហើយត្រូវការជំនួយក្នុងការចាប់ផ្តើមជាមួយ OR PTC DCI, ចង់បញ្ជាក់ឈ្មោះគណនីរបស់អ្នក ឬមានបញ្ហាទាក់ទងនឹងការបង់ប្រាក់ឈ្នួល សូមទាក់ទងទៅលេខ 503-945-9708 ឬ PC.20@odhsoha.oregon.gov ។

ប្រសិនបើអ្នកមានសំណួរអំពីចំនួនម៉ោងដែលបានអនុញ្ញាត ការលើកលែង ផែនការសេវាកម្ម ឬកិច្ចការងារ សូមទាក់ទង Comagine តាមរយៈលេខ 888-416-3184 ឬ ORBHSupport@comagine.org ។

## ជំនួយបច្ចេកទេសពី DCI

ទូរស័ព្ទទៅលេខ 1-855-565-0155 ឬអ៊ីមែលទៅ ORPTCSupport@dcisoftware.com

សម្រាប់ជំនួយជាមួយ៖

- ការប្រើប្រព័ន្ធជាមូលដ្ឋាន
- ចូលក្នុងគណនី, និង
- កំហុសនៃប្រព័ន្ធ (គេហទំព័រយឺតអត់ដើរ មានបញ្ហាផ្សេងៗ។ល។)

## ជំនួយចុះម៉ោងធ្វើការរបស់អ្នកផ្តល់សេវាមើលថែ

អ៊ីមែលទៅ PTC.Support@odhsoha.oregon.gov

ប្រសិនបើអ្នកមិនអាចទទួលបានជំនួយដែលអ្នកត្រូវការពីធនធានណាមួយផ្សេងទៀត។

## សំណួរដែលគេសួរជាញឹកញាប់ (FAQs)

ខាងក្រោមនេះគឺជាបញ្ជីសំណួរទូទៅដែលសួរដោយអ្នកផ្ដល់សេវាមើលថែ និងអ្នកទទួលការមើលថែ។ សម្រាប់បញ្ជីចុងក្រោយបំផុតនៃសំណួរដែលសួរជាញឹកញាប់ សូមចូលទៅកាន់ PTC.Oregon.gov ។

### តើមានការលើកលែងមិនចាំបាច់ប្រើ OR PTC DCI ដែរឬទេ?

### តើខ្ញុំអាចបន្តប្រើក្រដាសសរសេរម៉ោងធ្វើការបានដែរទេ?

មិនបានទេ។ តាមការតម្រូវការរបស់សហព័ន្ធ ក្រដាសសរសេរម៉ោងធ្វើការមិនអាចប្រើប្រាស់បានទៀតទេសម្រាប់រយៈពេលបច្ចុប្បន្ន ឬនាពេលអនាគត។ អ្នកផ្ដល់សេវាមើលថែត្រូវតែប្រើ OR PTC DCI ដើម្បីវាយបញ្ចូលម៉ោងធ្វើការរបស់ពួកគេតាមប្រព័ន្ធអេឡិចត្រូនិក។

### ចុះប្រសិនបើខ្ញុំត្រូវការជំនួយក្នុងការសម្រេចចិត្តលើជម្រើស OR PTC DCI ណាដែលល្អបំផុតសម្រាប់ខ្ញុំ?

ទាក់ទងទៅបុគ្គលិកកាន់សំណុំរឿងរបស់អ្នកទទួលការមើលថែគឺជាជំហានដំបូងដ៏ល្អ។ ប្រាប់គាត់នូវប្រភេទនៃបច្ចេកវិទ្យាណាមួយដែលអ្នកមានលទ្ធភាពប្រើប្រាស់ ហើយពួកគាត់អាចជួយអ្នកក្នុងការកំណត់ថាតើជម្រើស OR PTC DCI ណាមួយដែលត្រូវនឹងអ្វីដែលអ្នកមាន។ អ្នកក៏អាចស្វែងរកធនធានដើម្បីជួយអ្នកក្នុងការសម្រេចចិត្តបាននៅ PTC.Oregon.gov ។

### តើមានភាសា និងមុខងារអ្វីខ្លះដែលមាននៅក្នុង OR PTC DCI?

OR PTC DCI អនុវត្តតាមស្តង់ដាររបស់សហព័ន្ធ ហើយអ្នកដែលចេះអានអក្សរក្រង់បានអាចប្រើវាបាន។ វាមានសរសេរជាភាសាអង់គ្លេស អេស្ប៉ាញ រុស្ស៊ី ចិន វៀតណាម អារ៉ាប់ និងសូម៉ាលី។ ភាសាផ្សេងទៀតនឹងត្រូវបានគេបញ្ចូលបន្ថែមក្នុងពេលឆាប់ៗនេះ។

ឯកសារបណ្តុះបណ្តាល និង ម៉ោងពេលតាមប្រអប់ fob ពី OR PTC DCI មានសរសេរជាភាសាអង់គ្លេស អេស្ប៉ាញ អារ៉ាប់ ហ្វាស៊ី ខ្មែរ កូរ៉េ ឡាវ នេប៉ាល់ រ៉ូម៉ានី រុស្ស៊ី ចិនកុកងឺ សូម៉ាលី អេស្បាញ ចិនកាជីវ និងវៀតណាម។

**តើមានអ្វីកើតឡើងប្រសិនបើអ្នកផ្តល់សេវាមើលថែរាយម៉ោងធ្វើការលើសពីម៉ោងដែលបានអនុញ្ញាតរបស់ពួកគេនៅក្នុង OR PTC DCI?**

ប្រសិនបើការរាយបញ្ចូលម៉ោងធ្វើការរបស់អ្នកធ្វើលើសពីម៉ោងដែលបានអនុញ្ញាតរបស់អ្នក វានឹងបណ្តាលឱ្យខុសគ្នាជាមួយម៉ោងក្នុងប្រព័ន្ធ OR PTC DCI ។ អ្នកនឹងនៅតែអាចរាយម៉ោងនោះចូលបាន ប៉ុន្តែម៉ោងដែលលើសទាំងនោះនឹងមិនត្រូវបានគេបង់ប្រាក់ឈ្នួលអោយទេ រហូតទាល់តែវាត្រូវបានគេកែសម្រួលឱ្យស្ថិតក្នុងម៉ោងដែលបានអនុញ្ញាតវិញ។ សូមមើលឯកសារសិក្សានៅលើ OR PTC DCI ដើម្បីស្វែងយល់បន្ថែមអំពីរបៀបកែសម្រួលម៉ោងធ្វើការរបស់អ្នក។

**តើអ្នកផ្តល់សេវាមើលថែជាច្រើននាក់អាចចូលក្នុងគណនី និងធ្វើការអោយអ្នកទទួលការមើលថែតែម្នាក់ ក្នុងពេលតែមួយនៅក្នុង OR PTC DCI បានដែរឬទេ?**

បាន, ពួកគាត់អាចធ្វើបាន។

**ក្រដាសសរសេរម៉ោងកាលពីមុន អ្នកផ្តល់សេវាមើលថែអាចសរសេរកំណត់ត្រានៅខាងក្រោយក្រដាសនោះនូវកិច្ចការដែលបានធ្វើ។ តើវានឹងមានដូចគ្នានៅក្នុង OR PTC DCI ដែរឬទេ?**

មាន, អ្នកផ្តល់សេវាមើលថែអាចសរសេរកំណត់ត្រាពេលដែលគាត់បញ្ចូលម៉ោងធ្វើការនៅលើ OR PTC DCI (នៅក្នុងវិបផតថល ឬកម្មវិធីទូរស័ព្ទដៃ)។ បុគ្គលិកកាន់សំណុំរឿងនឹងអាចមើលកំណត់ត្រាទាំងនោះនៅក្នុង OR PTC DCI បាន។ កំណត់ត្រាគឺចង់សរសេរក៏បាន មិនសរសេរក៏បាន ហើយមិនត្រូវប្រើវាសម្រាប់ការទំនាក់ទំនងពេលមានអាសន្ននោះទេ។